ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីស្លាប់ជនជាតិខ្មែរចំនួនបីនាក់ ស្ត្រីអាយុ ៧៩ឆ្នាំ ស្ត្រីអាយុ ៥៩ឆ្នាំ និងបុរសអាយុ ៥៧ឆ្នាំ ដោយសារ ជំងឺកូវីដ-១៩

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា យោងតាមរបាយការណ៍៖

១- មន្ទីរពេទ្យហ្លួងម៉ែ បានឱ្យដឹងថាស្ត្រីជនជាតិខ្មែរ អាយុ ៧៩ឆ្នាំ រស់នៅសង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ត្រូវបានរកឃើញវិជ្ជមានកូវីដ-១៩ និងបានចូលសម្រាកមន្ទីរពេទ្យនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៦:០៥នាទី ជាមួយនឹងស្ថានភាព ក្អក ហត់ខ្លាំង។ ដោយស្ថានភាពជំងឺមានការវិវត្តកាន់តែធ្ងន់ធ្ងរឡើងៗ រហូតដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ តម្រូវឱ្យក្រុមគ្រូពេទ្យប្រើប្រាស់ម៉ាស៊ីនជំនួយដង្ហើម និងវិធីសង្គ្រោះផ្សេងទៀតតាមលក្ខណៈបច្ចេកទេស នៅតែមិនអាចជួយសង្គ្រោះអ្នកជំងឺបាន គាត់បានស្លាប់បាត់បង់ជីវិតនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៣:០០នាទី។

២- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងថាស្ត្រីជនជាតិខ្មែរ អាយុ ៥៩ឆ្នាំ មានអាសយដ្ឋាន រស់នៅសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ បានចូលសម្រាកនៅមន្ទីរពេទ្យ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ២១:០០នាទី ជាមួយនឹងស្ថានភាពហត់ដង្ហក់ខ្លាំងតម្រូវឱ្យក្រុមគ្រូពេទ្យព្យាបាលសង្គ្រោះបន្ទាន់ ដោយប្រើម៉ាស៊ីនជំនួយដង្ហើម និងយកសំណាកទៅវិភាគជាលទ្ធផលបង្ហាញថាស្ត្រីខាងលើមានវិជ្ជមានកូវីដ-១៩។ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ អ្នកជំងឺមានការវិវត្តកាន់តែធ្ងន់ធ្ងរឡើងៗ ដែលតម្រូវឱ្យគ្រូពេទ្យធ្វើការសង្គ្រោះតាមលក្ខណៈបច្ចេកទេស នៅតែមិនអាចជួយសង្គ្រោះបាន គាត់បានស្លាប់បាត់បង់ជីវិតនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០០:៣០នាទី។

**ការសន្និដ្ឋានរបស់ក្រុមគ្រូពេទ្យ៖** ស្ត្រីជនជាតិខ្មែរទាំងពីរនាក់ខាងលើបានស្លាប់បាត់បង់ជីវិតដោយសារវិបត្តិផ្លូវដង្ហើមស្រួចស្រាវ ធ្ងន់ធ្ងរ និងរលាកសួតទាំងសងខាង ដោយសារវីរុសកូវីដ-១៩។

៣- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងថាបុរសជនជាតិខ្មែរ អាយុ ៥៧ឆ្នាំ រស់នៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានចូលមកមន្ទីរពេទ្យនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៦:៤០នាទីព្រឹក ជាមួយនឹងស្ថានភាពស្លាប់ បាត់បង់ជីវិតរួចទៅហើយមុនពេលចូលដល់មន្ទីរពេទ្យ ដោយជាករណីសង្ស័យសពត្រូវបានយកសំណាកធ្វើវិភាគ ជាលទ្ធផលបញ្ជាក់ថាមានវិជ្ជមានកូវីដ-១៩។

**ការសន្និដ្ឋានរបស់ក្រុមគ្រូពេទ្យ៖** បុរសជនជាតិខ្មែរខាងលើបានស្លាប់ដោយសារជំងឺកូវីដ-១៩ មុនពេលចូលដល់មន្ទីរពេទ្យ (MOURANT ENTRANT AVEC COVID -19)។

ក្រសួងសុខាភិបាល សូមចូលរួមចំណែកសោកស្តាយជាពន់ពេក និងសូមចូលរួមមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុតជាមួយក្រុមគ្រួសារសព។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ២កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១